TKI0753

# សម្ភាសន៍ជាមួយ ប៉ាវ ញ៉ឹន ភេទស្រី អាយុ៦០ឆ្នាំ

## មុខងារៈ នារីពេទ្យ

## រស់នៅភូមិហាន់ទា ឃុំកំពែង ស្រុកគិរីវង់ ខេត្តតាកែវ

## ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ សុខ វណ្ណៈ

**Video:00:52:10**

**២៦ទំព័រ**

វណ្ណៈ  ថ្ងៃនឹងថ្ងៃទី១៥ ខែកក្កដា ខែ៧ ឆ្នាំ២០១០ បទសម្ភាសន៍ខាងPA ។ មុនដំបូងខ្ញុំសុំណែនាំខ្លួនថា ខ្ញុំមកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំនេះឈ្មោះសុខ វណ្ណៈ ។ ហើយខ្ញុំមកជួបអ៊ំដើម្បីចង់ដឹងរឿងរ៉ាវដែលកើតឡើងនៅក្នុងជំនាន់ខ្មែរក្រហម ឬមុនជំនាន់ខ្មែរក្រហមអី ដើម្បីឲ្យកូនក្មេងជំនាន់ក្រោយបានដឹង បានឮថាជំនាន់នឹងជួបការលំបាកយ៉ាងម៉េចខ្លះ ហើយស្រុកយើងមានលក្ខណៈយ៉ាងម៉េចនៅក្នុងសម័យនឹង ដើម្បីកត់ត្រាទុកជាប្រវត្តិសាស្ត្រ ដើម្បីបញ្ជ្រៀនចូលកម្មវិធីបង្រៀនក្មេងៗឲ្យយល់ពីកាលសម័យនឹង ។ មានតែយើងចាស់ៗទេបានដឹងរឿងរ៉ាវ ដល់ពេលយើងអត់បាននិយាយប្រាប់ក្មេងៗ ពេលស្លាប់បាត់បង់ទៅគ្មានអ្នកណានិយាយប្រាប់ដឹងរឿងនឹងដឹងទៀតទេ ។ អីចឹងក្មេងៗវាអត់យល់ វាអត់ដឹង វាអត់ជឿ សូម្បីឥឡូវនឹងថាអត់ជឿ ថាមាននរណាទៅស៊ីគល់ចេក គល់ក្ដាតទៀតទេ ។ វាខុសពីសម័យឥឡូវក៏សម័យសង្គមរាស្ត្រនិយម វាខុសគ្នាអីចឹង មានតែជំនាន់ខ្មែរក្រហមទេ ដែលប្រជាជននឹងជួបការលំបាកវេទនា ។ ខ្ញុំមុននឹងសម្ភាសន៍អ៊ំ ខ្ញុំសុំការអនុញ្ញាត តើអ៊ំអាចឲ្យខ្ញុំសម្ភាសន៍ បានដែរអត់?

ញ៉ឹន :  ចុះមានទាស់អី ។

វណ្ណៈ  ហើយបទសម្ភាសន៍របស់អ៊ំនឹង អាចឲ្យខ្ញុំយកទៅសរសេរជាសៀវភៅកត់ត្រាទុកជាប្រវត្តិសាស្ត្របានទេ?

ញ៉ឹន :  បាន ។

វណ្ណៈ  អ៊ំមិនជំទាស់ទេ?

ញ៉ឹន :  ចា៎ស ។

វណ្ណៈ  មុននឹងចាប់ផ្ដើមសម្ភាសន៍អ៊ំនៅក្នុងសម័យនឹង ខ្ញុំចង់ស្គាល់អ៊ំសិន អ៊ំឈ្មោះអីដែរ?

ញ៉ឹន :  ឈ្មោះ ប៉ាវ ញ៉ឹន ។

វណ្ណៈ ឈ្មោះ ប៉ាវ ញ៉ន?

ញ៉ន ៈ ចា៎ស!

វណ្ណៈ អ៊ំអាយុប៉ុន្មាន?

ញ៉ន ៈ ខ្ញុំ៦០ហើយ ។

វណ្ណៈ សព្វថ្ងៃអ៊ំរស់នៅភូមិអីដែរ?

ញ៉ន ៈ ភូមិហាន់ទា ។

វណ្ណៈ ភូមិហាន់ទា ឃុំ?

ញ៉ន ៈ កំពែង ។

វណ្ណៈ ស្រុកគីរីវង់?

ញ៉ន ៈ ចា៎ស!

វណ្ណៈ ខេត្តតាកែវ?

ញ៉ន ៈ ចា៎ស!

វណ្ណៈ ជំនាន់អ៊ំ កំណើតកើតជានៅណាដែរ?

ញ៉ន ៈ នៅស្រុកហ្នឹង ។

វណ្ណៈ ហើយគ្រួសារអ៊ំឈ្មោះអីដែរ?

ញ៉ន ៈ គ្រួសារស្លាប់យូរ ។

វណ្ណៈ ឈ្មោះអី គាត់ឈ្មោះអី?

ញ៉ន ៈ សំ ណែត ។

វណ្ណៈ ស្លាប់ជំនាន់ណា?

ញ៉ន ៈ មក តានីងមិនស្រួល៨២ហើយដឹង ។

វណ្ណៈ អូ! បែក៧៩ហើយ?

ញ៉ន ៈ ចា៎ស!

វណ្ណៈ គាត់ស្លាប់ដោយសារជម្ងឺ?

ញ៉ន ៈ ចា៎ស!

វណ្ណៈ ស្លាប់ដោយសារអីជម្ងឺ?

ញ៉ន ៈ ជម្ងឺ ។

វណ្ណៈ គ្រួសារអ៊ំរៀបគាំងពីជំនាន់ណាមក?

ញ៉ីន : ប៉ុលពតនឹង ។

វណ្ណៈ ជំនាន់ប៉ុលពតរៀបឲ្យ?

ញ៉ីន : ចា៎ស!

វណ្ណៈ ហើយសល់កូនចៅប៉ុន្មាននាក់សព្វថ្ងៃនេះ?

ញ៉ីន : មានតែ២ ។

វណ្ណៈ នៅជុំគ្នា?

ញ៉ីន : ជុំ ។

វណ្ណៈ អ៊ីចឹង៣ស្លាប់មួយ?

ញ៉ីន : អូ! កូនច្រើនណាស់ ។

វណ្ណៈ ប៉ុន្មាន?

ញ៉ីន : ៧នោះ ។

វណ្ណៈ អូ! ៧នាក់?

ញ៉ីន : ចា៎ស! តែស្លាប់អស់ហើយនៅតែ២ ។

វណ្ណៈ ស្លាប់អស់ប៉ុន្មាន?

ញ៉ីន : ស្លាប់អស់៥ ។

វណ្ណៈ ស្លាប់៥ ដោយសារជម្ងឺ ឬដោយសារអី?

ញ៉ីន : ដោយ មួយទៅធ្វើកងទ័ព ។

វណ្ណៈ ទៀត២?

ញ៉ីន : ២ស្លាប់ដោយជម្ងឺ ។

វណ្ណៈ ស្លាប់ដោយជម្ងឺឆ្នាំណា កងទ័ពឆ្នាំណា កងទ័ពចូលទៅ?

ញ៉ីន : វាបាត់កាលប៉ៃលិននឹង ។

វណ្ណៈ ប៉ៃលិនសម័យឥឡូវ?

ញ៉ីន : ចា៎ស!

វណ្ណៈ ក្រោយ៧៩ ចុះជម្ងឺទី២ស្លាប់?

ញ៉ីន : ហ្នឹងឆ្នាំ៧០ ហឺៗចុះមកបាន២ឆ្នាំ ។

វណ្ណៈ ក្រោយ៧៩ទាំងអស់?

ញ៉ីន : ចា៎ស!

វណ្ណៈ ទី៣នឹងក៏ស្លាប់ដោយក្រោយ៧៩ដែរ?

ញ៉ន : ចា៎ស!

វណ្ណៈ ទី៤នឹងក៏ក្រោយ៧៩ដែរ?

ញ៉ន : ចា៎ស!

វណ្ណៈ អីចឹង៥នាក់ ស្លាប់ច្រើន ស្លាប់ដោយសារជម្ងឺទាំងអស់?

ញ៉ន : ស្លាប់ទាំងអស់ៗ មានពេទ្យណាមុនដំបូងៗ

វណ្ណៈ ឈឺស្លាប់នៅភូមិនេះម៉ង?

ញ៉ន : ភូមិនឹងម៉ងៗ

វណ្ណៈ ចុះស្លាប់ដោយសារជម្ងឺ ដោយគ្មានថ្នាំ ក្រោយ៧៩?

ញ៉ន : ចា៎ស!

វណ្ណៈ ក្រោយ៧៩អត់មានថ្នាំគ្រប់គ្រាន់ទៀត ថាជំនាន់ប៉ុលពតខ្វះៗ ចុះមីងខ្ញុំចង់សួរមីងបន្តទៀត ហេតុអីបានមីងមានចិត្តចូលទៅបម្រើពេទ្យ មីងយល់ឃើញយ៉ាងម៉េចបានទៅ?

ញ៉ន : អានឹងយើងនិយាយកាលខ្ញុំមានប្តីមុន កាលពីមុនមកមានប្តីទាហានៗ

វណ្ណៈ ទាហានអីគេ ទាហានលន់ នល់ ទាហានអី?

ញ៉ន : អត់ទេ ទាហានកាលយើងពីដើមៗ

វណ្ណៈ ទាហានខាងខ្មែរក្រហម ឬក៏ទាហានខាងសម្តេចសីហនុ?

ញ៉ន : សម្តេចសីហនុ ចុះចេញៗមកឆ្នាំ៧០ ៗ

វណ្ណៈ ខ្ញុំចង់សួរបកទៅវិញ កាលពីក្មេងមីងរស់នៅភូមិនឹងហើយបានរៀនបានរៀនបានសូត្រអីទេ?

ញ៉ន : ខ្ញុំអត់ទេៗ

វណ្ណៈ អត់បានរៀន អត់ចេះអក្សរសោះ?

ញ៉ន : អត់ៗចេះៗ

វណ្ណៈ មកដល់សព្វថ្ងៃនេះ អត់ចេះដែរ?

ញ៉ន : អត់ រៀនអក្ខរកម្មមិនចេះៗ

វណ្ណៈ មីងរៀបការប្តីដំបូងនឹង រៀបនៅឆ្នាំណា?

ញ៉ន : ឆ្នាំ៦៧ ៗ

វណ្ណៈ ៦៧?

ញ៉ន : ចា៎ស!

វណ្ណៈ ហើយកាលនឹងគាត់ធ្វើជាទាហាននៅណា?

ញ៉ន : ទាហាននៅ១០៨ ។

វណ្ណៈ ១០៨នៅខេត្តតាកែវដែរ ឬនៅភ្នំពេញ?

ញ៉ន : ហ៎ា!មិនទេ អានឹងកោះអណ្ដែត អឺ!១០៨ហើយ ។

វណ្ណៈ អ៊ំដឹងទាហានៗខាងអី?

ញ៉ន : កាលនឹងទាហាន សម្ដេចយើងនឹង ។

វណ្ណៈ សម្ដេចសីហនុ?

ញ៉ន : ចា៎ស!

វណ្ណៈ ចុះក្រោយមកទៀត?

ញ៉ន : ក្រោយមកទៀត បានប្ដីខ្ញុំធ្វើចូល គេថាម៉ាក់គីចូលព្រៃនោះ ។

វណ្ណៈ ចូលម៉ាក់គីវិញ?

ញ៉ន : ចា៎ស!

វណ្ណៈ ប្ដីអ៊ំមុនឈ្មោះអី?

ញ៉ន : ស៊ីម ស៊ីម៉ន ។

វណ្ណៈ ស៊ីម ស៊ីម៉ន?

ញ៉ន : ចា៎ស!

វណ្ណៈ អីចឹងមានន័យថាចូលតាម ដូចថាគាត់ចូលៗតាមអីគេ គាត់ចូលតាមការឃោសនា ឬក៏ចូលតាមអីគេ?

ញ៉ន : ចា៎ស! ចូលតាមឃោសនា កាលនឹងសម្ដេចៗយើងមិនឲ្យចូលម៉ាក់គី រួចមកដល់ឆ្នាំ៧២នឹងគេបាញ់ផាប់ទៅ ។

វណ្ណៈ តាមការឃោសនារបស់សម្ដេច?

ញ៉ន : ចា៎ស!

វណ្ណៈ ហើយដល់ពេលឃោធា រហូតដល់ឆ្នាំ?

ញ៉ន : ៧២ ។

វណ្ណៈ ១៩៧២ បាញ់ជាមួយទាហានលន់ នល់?

ញ៉ន : ចា៎ស!

វណ្ណៈ ទាហានលន់ នល់ ស្លាប់នៅកន្លែងណា ម្ដុំណា?

ញ៉ន ៖ ស្លាប់នៅនឹងគេហៅព្រៃក្តួច ។

វណ្ណៈ ព្រៃក្តួចនឹងស្រុកណា?

ញ៉ន ៖ ព្រៃក្តួចនេះយើងនេះ ។

វណ្ណៈ ស្រុកគិរីវង់ដែរ?

ញ៉ន ៖ មិនទេ អានឹងខេត្តកំពត ។ ហៅព្រៃក្តួចជិតតាកែវយើងនេះ ។

វណ្ណៈ ព្រៃក្តួច ខេត្តកំពត?

ញ៉ន ៖ ចាស៎! ដំណាក់ក្រសាំង ម្តុំដំណាក់ក្រសាំង ព្រៃក្តួចនឹង ។

វណ្ណៈ តាកែវដែរទេ?

ញ៉ន ៖ ហ៎! អានឹងដឹងខេត្តតាកែវ ខេត្តកំពតមិនដឹង អណ្តែងសាំង ។

វណ្ណៈ ប៉ុនមិនដឹងស្រុកអី ត្រាំកក់ហើយខាងអី?

ញ៉ន ៖ ហ្នឹងមិនស្រួលត្រាំកក់ដែរដឹង ។

វណ្ណៈ ហេតុអីបានអ៊ំដឹងថាប្តីស្លាប់?

ញ៉ន ៖ គេហៅទៅ ។

វណ្ណៈ គេហៅទៅ?

ញ៉ន ៖ ទៅយកខ្មោចយកមកកប់ ។

វណ្ណៈ ហើយអ៊ំបានឃើញប្តីអ៊ំដាក់ស្អែងហើយ?

ញ៉ន ៖ ឃើញ បាញ់ចំចុងចិញ្ចើម កាលនឹងគាត់ធ្វើកងវរៈ មេទាហាន មេទ័ព ។

វណ្ណៈ ប្រធានវរៈដែរ?

ញ៉ន ៖ ចាស៎! ហើយទៅចូលនិមន្តលោកឲ្យចេញពីវត្តនោះ ។

វណ្ណៈ ចូលនិមន្តលោកម៉េច?

ញ៉ន ៖ ចូលនិមន្តលោកឲ្យចេញពីវត្ត ហើយអាងគេបាញ់គ្នា ដល់រួចលោកនឹងបាញ់បណ្តោយ ។

វណ្ណៈ ម៉េចបានដឹងថាលោកបាញ់ ព្រោះលោកកាន់ព្រះពុទ្ធសាសនា?

ញ៉ន ៖ ចុះនៅអង្គុយនឹងហើយដល់ចូលអីចឹង
យើងគ្រាន់ថ្វាយបង្គំទៅពីថ្វាយបង្គំគេបាញ់នឹងបណ្តោយ

វណ្ណៈ អីចឹងលោកសង្ឃបាញ់?

ញ៉ន ៖ ចាស៎!

វណ្ណៈ អ៊ំសន្និដ្ឋានយ៉ាងម៉េចបានជាថាលោកសង្ឃបាញ់?

ញ៉ន : បើកូនចៅគាត់ថា គេអ្នកទៅផ្ទាល់ជាមួយកងការពារគាត់នឹង ។

វណ្ណៈ អីចឹងលោកសង្ឃនឹងជាគិញដេរ?

ញ៉ន : ទាហានៗ ចា៎ស!ទាហានម៉ង ទាល់តែគេធ្វើលោកសង្ឃអីចឹង ហើយយើងស្តាប់សភាពការណ៍មិនបាន ។

វណ្ណៈ គេទាហានលន់ នល់ដែរ?

ញ៉ន : ចា៎ស!

វណ្ណៈ ចុះបើសិនជាអ៊ំអះអាងបែបនឹង ដោយសារថាកូនទាហានប្រាប់ កូនទាហានឃើញ កូនទាហានឈ្មោះអី?

ញ៉ន : អត់ស្គាល់ឈ្មោះគេផងខ្ញុំ ។

វណ្ណៈ អីចឹងអ៊ំក្រោយពីប្តីស្លាប់ដោយសារសង្គ្រាមអីចឹងទៅ កាលនឹងអ៊ំមានកូននៅ?

ញ៉ន : មានកូនមួយ ។

វណ្ណៈ មានកូនមួយហើយ?

ញ៉ន : ចា៎ស!

វណ្ណៈ មានកូនមួយហើយ ជាមួយប្តីអ៊ំនឹង?

ញ៉ន : ចា៎ស!

វណ្ណៈ ប្តីអ៊ំត្រូវបានបូជា បូអីនៅមាន មិនទាន់ហាមឃាត់ នៅមានលោក?

ញ៉ន : អត់ទេ បានបូជា មានលោក ។

វណ្ណៈ នៅមានលោកដែរ នៅឆ្នាំ៧២ ។ ក្រោយប្តីអ៊ំស្លាប់ទៅ អ៊ំទៅណាទៀតទៅ?

ញ៉ន : បានគេហៅយើងចូលតាមឯកភាពគេ ក្នុងអង្គភាពគេនឹងទៅ ។

វណ្ណៈ អីចឹងអ៊ំប្តីស្លាប់ភ្លាម ចូលបដិវត្តភ្លាម?

ញ៉ន : ចា៎ស!

វណ្ណៈ នៅឆ្នាំ១៩៧២នឹង?

ញ៉ន : ចា៎ស!

វណ្ណៈ ធ្វើពេទ្យភ្លាម ឬក៏ជាយោធាអីដែរ?

ញ៉ន : មុនដំបូងគេឲ្យបោះថ្នាំពេទ្យ ។

វណ្ណៈ ពេទ្យបណ្តោយ?

ញ៉ន : ចា៎ស!

វណ្ណៈ  បោះថ្នាំពេទ្យម៉េច?

ញ៉ន  :  ថ្នាំយើងលេបនឹង គ្រាប់ៗដូចអាចម៍ទន្សាយ ។

វណ្ណៈ  យកអីទៅធ្វើ?

ញ៉ន  :  កាលនឹង យកស្លែងយើងនឹង ជំឡូងមី អានឹងយើងធ្វើថ្នាំនឹង ។

វណ្ណៈ  ថ្នាំអាចម៍ទន្សាយនឹង ដូចថាយកផ្លែស្លែង?

ញ៉ន  :  ជំឡូងមីង ក្ដួច ។

វណ្ណៈ  ជំឡូងមីង ក្ដួច ម៉េចទៀត?

ញ៉ន  :  មានតែប៉ុននឹង ។

វណ្ណៈ  កិនចូលគ្នា?

ញ៉ន  :  អានឹងគេមិនកិនទេ គេយកទៅត្រាំៗហើយបុកៗ គេយកទៅស្រុះ យកអាម្សៅនឹងយកទៅធ្វើ ដល់លាយចូលគ្នា ។

វណ្ណៈ  យកទៅត្រាំទឹក?

ញ៉ន  :  ចា៎ស! យកត្រាំទឹក ។

វណ្ណៈ  ត្រាំទឹករួចបុក?

ញ៉ន  :  រួចបុកឲ្យម៉ត់ ហើយយកដាក់ត្រាំទឹក យកម្សៅចិតចោល ដល់យកអាម៉ត់ៗនឹង ។

វណ្ណៈ  ត្រាំទឹកបុកឲ្យម៉ត់ៗហើយធ្វើម៉េចទៀត?

ញ៉ន  :  ម៉ត់ហើយគេយកមកលាយចូលគ្នាទៅ មានទឹកឃ្មុំយើងអីខ្លះ បើគ្មានទឹកឃ្មុំគេយកស្ករដាក់ផ្អែមៗ ។

វណ្ណៈ  លាយជាមួយទឹកឃ្មុំ ។

ញ៉ន  :  អានឹងថ្នាំគ្រុន ។

វណ្ណៈ  បើអត់ទឹកឃ្មុំយកស្ករធ្វើ តែរបៀបធ្វើនឹង គេយកអីមូលៗ អាថ្នាំអាចម៍ទន្សាយនឹង?

ញ៉ន  :  មូលនឹងគេយកគ្រាប់កាំភ្លើងយើង អាកន្ទុះវានឹង ហើយដល់គេ ។

វណ្ណៈ  ចុចៗទៅ?

ញ៉ន  :  ចុចអី គេយកត្បាលអីចឹងហើយ គេយកឈើមួយដោតចំពាក់កណ្ដាល ហើយដល់យើងចុចអីទៅ ហើយដល់យើងរុញអីចឹងទៅចេញមកហើយ ដូចថ្នាំយើងអាថ្នាំនេះនឹងដូចប៉ាវ៉ាប៉ុនគ្នា ។

វណ្ណៈ  របៀបធ្វើគឺយកកន្ទុះកាំភ្លើង?

ញ៉ន  :  ចា៎ស! អានឹងធ្វើពុម្ព ។

វណ្ណៈ អាកាំភ្លើងអ៊ីមស៊ី ឬកាំភ្លើងអាកា អាតូចៗនឹង?

ញ៉ែន ៖ អាដូរិតនឹង អាតូច មានតូចមានធំ ។

វណ្ណៈ កន្ទុះកាំភ្លើង ចុចជាមួយមេរ្យ៉ានឹង ចេញជាថ្នាំ?

ញ៉ែន ៖ ចាស!

វណ្ណៈ ថ្នាំអាចម៌ទន្សាយ?

ញ៉ែន ៖ ចាស!

វណ្ណៈ តាមពិតខ្ញុំឮអ្នកស្រុកនិយាយថា អ៊ំថាថ្នាំគ្រុន ប៉ុន្តែអ្នកស្រុកថា ឈឺក្បាល ឈឺអីក៏ឲ្យអានឹងដែរ អានឹងជាការពិត ឬយ៉ាងម៉េច?

ញ៉ែន ៖ អានឹងមែនៗមិនកុហកទេ បើអាមូលៗខ្មៅៗនោះ អានឹងក៏គេឲ្យលេបដែរ អានឹងដូចតែគ្នាចេញពីនឹងមេរ្យ៉ាមីមេរ្យ៉ាអីដូចគ្នា ។ ស្លែងត្របកក៏បាន ផ្លែមិនដឹងរកផ្លែអាណាបានគេយកមកត្រាំ បុកហើយត្រាំទឹកនឹង គេច្រិតចោលទៅទឹកអាថ្លាៗ យកអាមេរ្យ៉ានឹងម៉ង មានយើងគ្មានស្អីត្រង់ទេ អត់ទេ យើងបុកហើយ យើងស្រង់អត់រលីង សំរិតចោលទៅ អត់មានសរសៃសរសូងអីទេ ក្លូចនឹងក៏អីចឹង ហើយដំឡូងមីក៏អីចឹងដែរ យើងឈូសៗឲ្យម៉ង ហើយស្រង់ចេញ ។ ហើយដល់ពេលវាថ្លា រង់ៗហើយ យើងច្រោះចោលទឹកថ្លាៗ យកអានឹងទៅ ។

វណ្ណៈ ចុះកាលនឹងអ៊ំចូលដោយមានការឈឺចាប់នឹងទាហានខាងនល់ នល់ ឬចូលដោយសារថាគេបន្ទុំ ឬក៏មានអ្នកនាំចូល ឬយ៉ាងម៉េច?

ញ៉ែន ៖ កាលនឹងគេហៅយើង គេថាប្រពន្ធកម្មាភិបាល គេឲ្យចូលម៉ង ។

វណ្ណៈ គេឲ្យចូល?

ញ៉ែន ៖ ចាស!

វណ្ណៈ ហើយអ៊ំមានចិត្តចង់ចូលដែរអត់ កាលនឹង?

ញ៉ែន ៖ កាលនឹងចង់ទៅរកម៉ែឪ តែគេមិនឲ្យយើងមក គេថាយើងប្រពន្ធកម្មាភិបាល ។

វណ្ណៈ ចុះអ៊ំកាលជំនាន់ខ្មែរក្រហម អ៊ំអត់បាននៅស្រុកភូមិនេះទេ?

ញ៉ែន ៖ ខ្ញុំនោះ?

វណ្ណៈ បាទ!

ញ៉ែន ៖ ខ្មែរក្រហមកាលឆ្នាំ៧០ ខ្ញុំមកនៅភូមិហ្នឹងហើយ ។

វណ្ណៈ ចុះពេលប្តីអ៊ំមកធ្វើអីនៅខាង?

ញ៉ែន ៖ អានឹងនៅផ្ទះ ។

វណ្ណៈ ចុះដល់ពេលចូលបម្រើការងារផ្នែកពេទ្យ ផ្នែកអី អ៊ំទៅធ្វើកន្លែងណា?

ញ៉ន ៈ ខ្ញុំកាលនឹងគេឲ្យនៅស្រុកលើនោះ ហើយដល់គេហៅ ។

វណ្ណៈ ស្រុកណា?

ញ៉ន ៈ មិត(វត់) ទៅលើ មានដែលនៅផ្ទះណា ។

វណ្ណៈ ឆ្នាំណា?

ញ៉ន ៈ កាលឆ្នាំ៧១ ខ្ញុំទៅៗតាមប្ដីនឹង ។

វណ្ណៈ តាមប្ដីរហូត ដល់ពេលប្ដីស្លាប់?

ញ៉ន ៈ ប្ដីស្លាប់ដូចថាគេនៅកងនៅឆ្ងាយ ឧបមាថាគេនៅទម្លាប់យើងនៅនឹង គេឲ្យស្នាក់នៅនឹង ។

វណ្ណៈ ខ្ញុំចង់ដឹងក្រោយពេលប្ដីអ៊ំស្លាប់វិញ អ៊ំធ្វើពេទ្យៗនឹងពេទ្យស្រុក?

ញ៉ន ៈ ស្រុក ។

វណ្ណៈ ស្រុកណា?

ញ៉ន ៈ ស្រុកគិរីវង់យើងនឹង ។

វណ្ណៈ ពេទ្យស្រុកគិរីវង់ កាលនឹងមានបុគ្គលិកពេទ្យទាំងអស់ប៉ុន្មាននាក់?

ញ៉ន ៈ កាលនឹងមានប៉ុន្មាន២៥នាក់នោះ ។

វណ្ណៈ ពេទ្យ២៥នាក់ កាលនឹងស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ញ៉ន ៈ ទេ! មិនបានរាប់ទេ ។

វណ្ណៈ ប្រហែលៗ?

ញ៉ន ៈ ប្រហែលកាលនឹង ប្រុសគេមិនសូវមានទេ ច្រើន៦-៧នាក់ ។

វណ្ណៈ ៦-៧នាក់?

ញ៉ន ៈ ចាស!

វណ្ណៈ ចុះប្រធានពេទ្យ?

ញ៉ន ៈ ប្រធានពេទ្យ កាលនឹង ទេ! សម្បត្តិ ។

វណ្ណៈ ឈ្មោះសម្បត្តិ?

ញ៉ន ៈ ដឹងនាមត្រកូលគេ ដឹងអីទេ ។

វណ្ណៈ សម្បត្តិស្រី ឬប្រុស?

ញ៉ន ៈ ស្រី ។

វណ្ណៈ សម្បត្តិនឹងគាត់ធ្វើការរហូតដល់៧៩ ឬក៏មានបាត់ខ្លួន ឬក៏ផ្លាស់ប្ដូរទៅខាងណា?

ញ៉ន ៖ គេផ្លាស់ទៅបាត់ ។

វណ្ណៈ បាត់ខ្លួនឆ្នាំណា?

ញ៉ន ៖ កាលឆ្នាំ៧៨ ។

វណ្ណៈ អឺ! ៧៨?

ញ៉ន ៖ ចា៎ស!

វណ្ណៈ ៧៨ អត់ទាន់ប៉ុលពតចូលមែនទែនទេ ៧៩បានចូល ។ ឥឡូវអ៊ំគិតមើល ស្រួលបួល?

ញ៉ន ៖ អឺចឹងហើយ៧៨ហើយ ផ្លាស់មកប្រធានថ្មីមួយទៀត ។

វណ្ណៈ ប្រធានថ្មីមួយទៀតឈ្មោះអី?

ញ៉ន ៖ ឈ្មោះរ៉ី ។

វណ្ណៈ ឈ្មោះ?

ញ៉ន ៖ ឈ្មោះរ៉ី នឹងម៉ង ពេទ្យរ៉ី ។

វណ្ណៈ រ៉ី?

ញ៉ន ៖ ចា៎ស!

វណ្ណៈ ឈ្មោះរ៉ី ស្រីដែរ?

ញ៉ន ៖ ប្រុស ។

វណ្ណៈ គាត់ធ្វើការរហូតដល់៧៩?

ញ៉ន ៖ ចា៎ស! រហូត ។

វណ្ណៈ កាន់រហូតដល់៧៩?

ញ៉ន ៖ ទល់បែក ទល់មើលគេរើស ចេញ ច្រើនផ្នែកណាស់ រឿងប្រធានពេទ្យនឹង ។

វណ្ណៈ ប៉ុន្តែតាមមើលម៉ាស្រុកមិនមែនមានតែ២៥នាក់នឹងទេ តាមអ៊ំគិត?

ញ៉ន ៖ តាមស្រុកអានឹងគេបែក ។

វណ្ណៈ អត់ទេម៉ាស្រុកតែមួយនឹង មានបុគ្គលិកពេទ្យទាំងអស់សរុបទាំងគ្រប់ផ្នែក អាខាងថ្នាំពេទ្យ ខាងចាក់ ខាងលាងរបួសអីទាំងអស់?

ញ៉ន ៖ ចា៎ស! មានតែប៉ុននឹងទេ អត់មានច្រើន ។

វណ្ណៈ អត់មានច្រើនលើសនឹងទេ?

ញ៉ន ៖ អានឹងដល់មូលតាមឃុំមក អានឹងបានច្រើន ។

វណ្ណៈ	ពេទ្យដូចអ៊ំធ្វើនឹង តាំងពី៧២រហូតមក ដល់ចូល៧៥ ៧៦ ៧៧ ៧៨ ៧៩ មានការផ្លាស់ប្តូរយ៉ាងម៉េចដែរ?

ញ៉ន ៖	ខ្ញុំចេញមក៧៧ អឺ!៧៦ ។

វណ្ណៈ	ចេញមកណាវិញ?

ញ៉ន ៖	ចេញពីពេទ្យមកនៅសហករណ៍ ។

វណ្ណៈ	ឧបមាថាពី៧២រហូតដល់៧៦នឹង តើអ៊ំធ្លាប់បានទៅរៀននៅភ្នំពេញ ទៅរៀនអីដែរ?

ញ៉ន ៖	អត់ទេ ទៅរៀននៅសាលាគេនឹង ។

វណ្ណៈ	សាលារៀន?

ញ៉ន ៖	សាលានៅស្រុកនឹងម៉ង ។

វណ្ណៈ	នៅសាលាស្រុកនឹងម៉ង?

ញ៉ន ៖	ចាស!

វណ្ណៈ	ចុះអ៊ំធ្លាប់ឃើញចិន ឬធ្លាប់ឃើញពីណាខ្លះមកទេ?

ញ៉ន ៖	អានឹងគេចុះមកនឹង ដូចថាយើងស្រុកនឹងគេមកៗកន្លែងពេទ្យនឹង គេមកមើលអីមួយភ្លែតៗនឹង ។

វណ្ណៈ	គណៈប្រតិភូមានពីណាខ្លះ មានខាង?

ញ៉ន ៖	អត់ស្គាល់ ។

វណ្ណៈ	មានចិនទេ?

ញ៉ន ៖	មានៗមក ។

វណ្ណៈ	មានចិនអីចុះមកមើលដែរ?

ញ៉ន ៖	ចាស!

វណ្ណៈ	កាលមកៗឡាន មកអី?

ញ៉ន ៖	គេកាលនឹងឡានរបស់គេដែរ ។

វណ្ណៈ	មកគ្នាច្រើន?

ញ៉ន ៖	មកតែ៣-៤នាក់នឹង ។

វណ្ណៈ	ពីណានាំមក តាម៉ុក ឬពីណា?

ញ៉ន ៖	តាម៉ុក តែមកដោយតាម៉ុកមក ។

វណ្ណៈ	អ៊ំស្គាល់តាម៉ុកច្បាស់?

ញ៉ន ៖ ចាស!

វណ្ណៈ ពេលតាម៉ុកមកដល់ពេទ្យ គណៈប្រតិភូចិនមកដល់ពេទ្យនឹង តើមកបង្រៀនពេទ្យបន្ថែម ឬក៏មកអប់រំ ឬក៏មកប្រាប់គោលការណ៍យ៉ាងម៉េច សម្រាប់អ្នកជម្ងឺឲ្យពេទ្យមើលការខុសត្រូវអីតាម៉ុកមានដែលនិយាយសន្ទរកថា?

ញ៉ន ៖ ខ្ញុំមិនដែលចូលអង្គប្រជុំទេធំៗអីចឹង ។

វណ្ណៈ ប៉ុន្តែ មកគាត់ដើរចូលតាមពេទ្យៗ គាត់មាននិយាយប្រាប់បុគ្គលិក?

ញ៉ន ៖ គេប្រជុំៗគេប្រធានៗ ខ្ញុំសមាជិកធ្វើម៉េចបានប្រជុំនឹងគេ ។

វណ្ណៈ អ៊ំកាលនោះអត់មានតួនាទីអីទេ ជាពេទ្យធម្មតា?

ញ៉ន ៖ ចាស!

វណ្ណៈ តើអ៊ំសង្កេតមើលថាពីឆ្នាំ៧៥ ពេលខ្មែរក្រហមកាន់កាប់មានសហករណ៍មានអី ហើយនឹងពេលនឹង ពី៧៥ ៧៦ ៧៧ តើអ៊ំសង្កេតឃើញអ្នកជម្ងឺប្រភេទអីខ្លះទៅ ឈឺៗដោយសារអីអ៊ំបានដឹងទេ?

ញ៉ន ៖ ក្នុងមន្ទីរស្រុក ប្រជាជនអត់បានចូលទេ មានតែកងទ័ព ។

វណ្ណៈ កងទ័ពវិញ?

ញ៉ន ៖ ចាស! មានតែកងទ័ព អានឹងតាមផ្លូវ ។

វណ្ណៈ អ៊ំនៅពី៧២ រហូតដល់៧៦?

ញ៉ន ៖ ចាស!

វណ្ណៈ មានកងទ័ពៗឈឺអី?

ញ៉ន ៖ តែរបួស គ្រុន ។

វណ្ណៈ គ្រុន ចុះប្រជាជនហេតុអីបានគេអត់ឲ្យយកទៅពេទ្យស្រុក?

ញ៉ន ៖ អត់ទេ ។

វណ្ណៈ ចុះប្រពន្ធកម្មាភិបាលៗឈឺអី?

ញ៉ន ៖ ដល់មកចូល៧៦នឹង អានឹងគេធ្វើផ្សេងអីចឹង មកផ្លាស់ទីនៅផ្សឹង អានឹងបានប្រជាជនចូលអានឹងបានចូលផ្លាស់ទៅ ។ រួចទៅបានខ្ញុំគេដេញចេញទៅ ។

វណ្ណៈ ចុះអ៊ំកាលអ៊ំនៅ ពេទ្យនឹងត្រូវរបួសៗដោយសារអី?

ញ៉ន ៖ ទៅបាញ់គ្នា ។

វណ្ណៈ បាញ់ជាមួយពីណា?

ញ៉ូន ៖ កាលនឹងមិនដឹង គេថាជាមួយយួន ។

វណ្ណៈ គេបាញ់ជាមួយយួនដល់ឆ្នាំ៧៨ហើយ?

ញ៉ូន ៖ ចាស! កាលនឹងបាញ់អីចឹង កាលខ្ញុំនៅបាញ់អីចឹង ដល់ពេលមកដល់៧៥ ៧៦អានឹងលែងហើយ លែងមានបាញ់ហើយ ។

វណ្ណៈ ខ្ញាចអ៊ំនិយាយច្រឡំ ពីព្រោះឆ្នាំពី៧០មកត្រូវយើងកើតសង្គ្រាមជាមួយលន់ នល់ បាញ់គ្នារហូតដល់៧៥លែងមានសង្គ្រាមអីទៀតហើយ ខ្មែរក្រហមទទួលបានហើយ ។ ទទួលបានពី៧៦ ៧៧នឹង អ៊ំថាមានទាហានរបួសទៀត ប៉ុន្តែបើតាមនឹងអត់ទាន់ទេ ពេលយើងបាញ់ជាមួយយួន៧៨ ចុង៧៧ ៧៨ បានយើងវ៉ៃជាមួយយួនទៀត អីចឹងបានទាហានមានរបួសម៉ាសារទៀត អ៊ំគិតមើលៗ?

ញ៉ូន ៖ ខ្ញុំមើល កាលខ្ញុំនៅ អានឹងវ៉ៃជាមួយយួនកាលឆ្នាំ៧៣ៗអានឹងខ្ញុំនៅពេទ្យដែរ ដល់៧៨ក៏នៅពេទ្យដែរ ។

វណ្ណៈ អានឹងនៅវ៉ៃជាមួយយួនដែរ?

ញ៉ូន ៖ ចាស! អានឹងនៅអីចឹង ។

វណ្ណៈ វ៉ៃជាមួយយួន ប៉ុន្តែវ៉ៃជាមួយទាហានលន់ នល់ យួនខាងត្បូង អាធៀវគឺនឹង?

ញ៉ូន ៖ ខាងត្បូង ។

វណ្ណៈ យួនធៀវគឺនឹងក៏វ៉ៃដែរ?

ញ៉ូន ៖ ដល់៧៥ត្រូវយើងរំដោះពីភ្នំពេញមក ។

វណ្ណៈ បាទ! ហើយម៉េចទៀត?

ញ៉ូន ៖ ដល់ហើយអីចឹងទៅ រួចទៅបានខ្ញុំចូល៧៦ គេឲ្យរៀបជាមួយតានឹង ខ្ញុំមិនរៀប គេមិនព្រមគេវ៉ៃយើងចោល ។

វណ្ណៈ តាមនឹងធ្វើអី?

ញ៉ូន ៖ តានឹងគាត់ខាងសេដ្ឋកិច្ច ។

វណ្ណៈ ខាងសេដ្ឋកិច្ច?

ញ៉ូន ៖ ចាស!

វណ្ណៈ ហើយអ៊ំរៀបការនៅឆ្នាំ១៩៧៦?

ញ៉ូន ៖ ចាស! ហើយដល់រួចទៅ ខ្ញុំរៀបអីហើយ គេដេញយើងឲ្យមកនៅសហករណ៍ ។

វណ្ណៈ អ៊ំរៀបការហើយមកនៅសហករណ៍វិញ?

ញ៉ីន ៖ ចាស!

វណ្ណៈ ប៉ុន្តែខ្ញុំចង់បកមកខាងផ្នែកពេទ្យនឹង អ៊ំមានតែទាហាន ឃើញទាហានអីរបួសទេ ពេលនឹង?

ញ៉ីន ៖ កាលឃើញតែពួកនឹង វាធ្វើនឹង ។

វណ្ណៈ ប៉ុន្តែនៅក្នុងសម័យនឹង ថ្នាំអីប្រើមានប្រសិទ្ធភាពខ្លះដែរ ឬក៏ម៉េច ដល់ពេលអ្នកទៅមើលជម្ងឺនៅនឹងស្ងាប់អីយ៉ាងម៉េច មាន?

ញ៉ីន ៖ ដូចមិនសូវអីដែរ ។

វណ្ណៈ ដូចមិនដូវអីដែរ?

ញ៉ីន ៖ អឺ! ដូចថាយើងនៅខ្វះ ដល់មកឆ្នាំ៧៦នឹង គេដេញកាលឲ្យខ្ញុំមកនៅសហករណ៍ គេផលិតអាទឹកយើង ។

វណ្ណៈ ទឹកអី?

ញ៉ីន ៖ អាស៊ីរ៉ូនឹងគេប្រើចំហ៊ុយ អានឹងគេដេញខ្ញុំចេញហើយ ។

វណ្ណៈ ចុះអ៊ំថាកាលនឹង យើងអត់មានស៊ីរ៉ូអីប្រើទឹកដូងទឹកអីនឹង តើជាការពិត ឬយ៉ាងម៉េច?

ញ៉ីន ៖ រឿងទឹកដូងពិត ការឆ្នាំ៧៣ទេ ពិត ។

វណ្ណៈ ចុះអានឹងគេយកទៅចាក់មនុស្សបានទេ?

ញ៉ីន ៖ ចាក់ ប៉ុនអត់មានទម្លាក់ទេ ចងខ្សែដាក់ម៉ង ។

វណ្ណៈ ទឹកដូងនឹងអត់មានទម្លាក់ដល់ដីទេ?

ញ៉ីន ៖ អត់ទេ ហ្នឹងចងខ្សែទម្លាក់ម៉ង ។

វណ្ណៈ ចងខ្សែទម្លាក់?

ញ៉ីន ៖ ចាស!

វណ្ណៈ ចងខ្សែមិនទម្លាក់ទេ តែថាទម្លាក់អត់បានទេ?

ញ៉ីន ៖ វាចេញសាច់ ។

វណ្ណៈ ពេលដូចថាពេទ្យស្រុកជួនកាលអីចឹងអត់មានបច្ចេកទេសអីទេ គឺហួសពីសមត្ថភាពពេទ្យស្រុក តើមានឡានគេបញ្ជូនទៅពេទ្យភ្នំពេញពេទ្យអីទេ អ្នករបួស អ្នកឈឺ?

ញ៉ីន ៖ អ្នករបួសធ្ងន់បញ្ជូនដែរ ។

វណ្ណៈ បញ្ជូនទៅពេទ្យភ្នំពេញ?

ញ៉ីន ៖ ចាស!

វណ្ណៈ អីចឹងដូចប្រពន្ធកម្មាភិបាល ឬប្រពន្ធអី គេអាចព្យាបាលនៅស្រុកបាន?

ញ៉ន ៖ បាន ។

វណ្ណៈ គ្រួសារកម្មាភិបាលបញ្ជូនទៅស្រុកបាន ប្រជាជនអត់បានទេ?

ញ៉ន ៖ អត់បានទេ អានឹងកាលឆ្នាំ៧២ គេសំងាត់របស់គេ ។

វណ្ណៈ ប្រពន្ធកម្មាភិបាលព្យាបាលពេទ្យស្រុកបាន ប្រជាជនមិនបាន ។ ចុះប្រជាជនគេ ពេលឈឺទៅណាវិញ បើពេទ្យស្រុកអត់ទទួលអីចឹង?

ញ៉ន ៖ នៅឃុំ ។

វណ្ណៈ ដេកពេទ្យឃុំ?

ញ៉ន ៖ ចាស!

វណ្ណៈ បើឃុំមើលអត់ជា បញ្ជូនទៅស្រុកបានអត់?

ញ៉ន ៖ បញ្ជូនបានទាល់តែនៅផ្សេងទៀត អត់មានចូលអាកន្លែងមន្ទីរគេ ។

វណ្ណៈ អីចឹងបានន័យថាពេទ្យស្រុកនឹងមានកន្លែងមួយទៀតសម្រាប់ដាក់ប្រជាជដែរ?

ញ៉ន ៖ ចាស! វាផ្សេងពីគ្នា ។

វណ្ណៈ ប្រជាជនដែលដាក់ម៉ាកន្លែងទៀតនឹង តាមពិតទៅគាត់ឈឺ ភាគច្រើនឈឺនឹងអី?

ញ៉ន ៖ ហើម ។

វណ្ណៈ ហើម?

ញ៉ន ៖ ហើមដូចអត់បាយ ទៅមិនជា ៗ ហើទៅ ងាប់ ៗ ទៅ ។

វណ្ណៈ ដោយសារអត់អាហារនឹង?

ញ៉ន ៖ ចាស!

វណ្ណៈ ចុះជម្ងឺដោយសារអត់អាហារនឹងពិបាកព្យាបាលទេ?

ញ៉ន ៖ ពិបាក យូរទៅហត់ហេវ ៗ ទៅ ចេះទៅ ៗ ។

វណ្ណៈ ស្លាប់ទៅ?

ញ៉ន ៖ ចាស!

វណ្ណៈ ពេលស្លាប់ទៅ តើគេមកហៅសាច់ញាតិមកទទួល ឬក៏គេកប់ចោល ៗ ទៅតែម្តង?

ញ៉ន ៖ បើនេះទេ គេបំបិទមិនឲ្យដឹង ។ គេអត់មានប្រាប់យើង កប់ចោល ។

វណ្ណៈ ភាគច្រើនគេមិនឲ្យបងប្អូនដឹង?

ញ៉ន ៖ អត់ឲ្យដឹង ។

វណ្ណៈ ចុះអ៊ំដូចអ៊ំធ្លាប់ធ្វើថ្នាំ ក្រៅពីធ្វើថ្នាំអាចម៍ទន្សាយមានថ្នាំស្អីផ្សេងទៀត?

ញ៉ន ៈ គ្មានទេ មានតែបោះថ្នាំ ។

វណ្ណៈ មានបោះថ្នាំអាចម៍ទន្សាយនឹង?

ញ៉ន ៈ ចាស!

វណ្ណៈ ចូលទៅធ្វើនឹង?

ញ៉ន ៈ ចាស!

វណ្ណៈ ប៉ុន្តែកាលនឹងមានថ្នាំជំនួយរបស់ចិន?

ញ៉ន ៈ មានខ្លះ តែវាមិនបានសំបូរបែប ។

វណ្ណៈ ម៉េចដឹងថារបស់ចិន?

ញ៉ន ៈ គេដាក់របស់ល្អ បើគេដាក់របស់ពីចិនមក អានឹងពួកគេនិយាយ ។

វណ្ណៈ មេនិយាយ?

ញ៉ន ៈ ចាស!

វណ្ណៈ យើងពួកតាមមេនិយាយ?

ញ៉ន ៈ ចាស!

វណ្ណៈ មេឈ្មោះរ៉ៃនឹង?

ញ៉ន ៈ ចាស!

វណ្ណៈ មេឈ្មោះរ៉ៃ ហើយរ៉ែន?

ញ៉ន ៈ រ៉ៃ គេនៅស្រុកលើ ។

វណ្ណៈ ចុះអ៊ំ ពេលដូចថានៅក្នុងសម័យនឹងអ៊ំមានចិត្តចង់ជួយទេ ឃើញប្រជាជនអីឈឺហើម ឈឺអី មានចិត្តចង់ជួយដែរ ឬក៏យ៉ាងម៉េច?

ញ៉ន ៈ ចង់ជួយដែរ តែយើងធ្វើមិនកើត ខ្ញុំលួចដែរនឹងថ្នាំ ។

វណ្ណៈ ចង់ជួយដែរ តែធ្វើមិនកើត ធ្វើមិនកើតដោយសារអី?

ញ៉ន ៈ ដោយសារយើងគ្មានថ្នាំ ។

វណ្ណៈ តាមអ៊ំគិតមើល តើថ្នាក់ដឹកនាំខ្មែរក្រហមនឹង បើយើងគ្រាន់គិតមើល តើគេយកប្រជាជន គេយកក្មេងៗដែលអត់ចេះអក្សរអីចឹងទៅធ្វើពេទ្យ ធ្វើអីនឹង គេមានចេតនាយ៉ាងម៉េចដែរ ឬក៏គេថាប្រជាជនស្លាប់ទៅអីយ៉ាងម៉េច?

ញ៉ន ៈ គេថាយើង យកទៅធ្វើពេទ្យនឹងដោយសារចេះតែម្នាក់២នាក់វាអាចប្រើកើត បើយើងល្ងង់នឹង គេស្រេចតែក្បាល ។

វណ្ណៈ គេយល់តែអីចឹង?

ញ៉ន ៖ ចាស!

វណ្ណៈ ចុះបើប្រជាជនមានគ្រោះថ្នាក់ដោយសារ យើងប្រើថ្នាំប្រឡូអី តើគេមានគិតខ្វល់ខ្វាយទេ?

ញ៉ន ៖ គេឲ្យអានេះចាក់អានេះ ស្រេចគេឲ្យយើងយកទៅចាក់ឲ្យ ។

វណ្ណៈ អ៊ំគិតថាខ្លួនឯង យើងគិតមើល ដូចគ្នាអ៊ំថា តើគេយកប្រជាជន គេយកក្មេងៗដែលអត់ចេះអក្សរអីចឹងទៅធ្វើពេទ្យធ្វើអីនឹង គេមានចេតនាយ៉ាងម៉េចដែរ ឬប្រជាជនស្លាប់ទៅយ៉ាងម៉េច?

ញ៉ន ៖ គេថាយើងគេយកទៅធ្វើពេទ្យ ចេះម្នាក់២នាក់វាអាចប្រើកើត ហើយបើយើងល្ងង់នឹង គេស្រេចតែគេប្រើទេ ។

វណ្ណៈ គេយល់ថាអីចឹង?

ញ៉ន ៖ ចាស!

វណ្ណៈ ចុះបើប្រជាជនមានគ្រោះថ្នាក់ដោយសារ យើងប្រើថ្នាំប្រឡូអី តើគេមានគិតខ្វល់ខ្វាយទេកាលនឹង?

ញ៉ន ៖ គេឲ្យអានេះយកចាក់អានេះ ស្រេចតែគេឲ្យយើងយកទៅចាក់ឲ្យ ។

វណ្ណៈ អីចឹង អ៊ំគិតថាខ្លួនឯង?

ញ៉ន ៖ ចាស!

វណ្ណៈ យើងគិតមើលដូចគ្នា តើមេដឹកនាំថ្នាក់កំពូល មេដឹកនាំខ្មែរក្រហមនឹង បានដឹងបានឮដែររឿងនឹង គាត់បានដឹងថានៅខាងក្រោមនឹងគ្មានថ្នាំព្យាបាល ឬក៏អ៊ី តើអ៊ំគិតថាពួកថ្នាក់លើបានដឹងទេ?

ញ៉ន ៖ បើគេថីមិនដឹង ទាល់តែថាថ្នាំៗផ្សះអានឹងជិនាញលើ ។

វណ្ណៈ អីចឹងថ្នាក់លើត្រូវបានដឹងហើយ?

ញ៉ន ៖ ចាស!

វណ្ណៈ តើអ៊ំថាកាលជំនាន់ខ្មែរក្រហម តើគេមានចេតនាថ្នាក់លើនឹង មានចេតនាចង់សម្លាប់ប្រជាជនយើង ឬក៏យ៉ាងម៉េចដែរ បើតាមអ៊ំគិត?

ញ៉ន ៖ រឿងពេទ្យអត់មាន ។

វណ្ណៈ ប៉ុន្តែបើសិនជាថ្នាក់លើៗគេ ហេតុអីគេអត់ឲ្យមនុស្សចេះដឹង ព្យាបាល អត់ឲ្យថ្នាំគ្រប់គ្រាន់អានឹងគេមានចេតនាយ៉ាងម៉េច?

ញ៉ន ៖ ទេ! មិនដឹងដែរ គំនិតគេ ខ្ញុំមិនដឹងដែរ ។

វណ្ណៈ ថ្នាក់លើហ្នឹងអ៊ំអត់ដឹងដែរ អត់ដឹងថាគេមានគំនិតយ៉ាងម៉េចទេ?

ញ៉ន ៖ ចា៎ស! អត់ដឹងទេ អានឹងគំនិតគេ ក្នុងខ្លួនយើងចេះចង់ជួយហើយ បើកាលខ្ញុំនៅចាក់នឹងច្រើន តែរបួស ហើយនឹងគ្រុននឹង តែ២មុខនឹង កាលខ្ញុំនៅធ្វើ ។

វណ្ណៈ ហើយនឹងប្រជាជនមួយចំនួនឈឺហើមអីចឹងទៅ ដោយសារអត់អាហារ?

ញ៉ន ៖ ចា៎ស! ច្រើនអត់អាហារ ។

វណ្ណៈ តែដូចថាពេទ្យមានចិត្តចង់ជួយដែរ តែដោយសារគ្មានថ្នាំ ឬយ៉ាងម៉េច?

ញ៉ន ៖ ចា៎ស!

វណ្ណៈ អ៊ំមិនបានដឹងគំនិតថ្នាក់លើនឹងចង់សម្លាប់ប្រជាជន ឬយ៉ាងម៉េច អ៊ំមិនបានដឹងទេ?

ញ៉ន ៖ មិនដឹងទេ ។

វណ្ណៈ ប៉ុន្តែបើអ៊ំគិតមើល អ៊ំគិតខ្លួនឯងមើលអ៊ំខ្លួនឯង គិតថាយ៉ាងម៉េចដែរ?

ញ៉ន ៖ ខ្ញុំគិតដល់យើងនៅក្នុងអត់ដឹងថាអ្នកណាអ្នកសម្លាប់អ្នកណាអត់ដឹង បើយើងមិនដែលបានមក ផ្ទះមកអីមិនដែរដឹងទេ ដល់ស្លាប់នៅកន្លែងមន្ទីរម៉ង់បានដឹង ។

វណ្ណៈ ដូចថាបុគ្គលិកពេទ្យដូចអ៊ំមានអ្នកបាត់ខ្លួន មានអ្នកដោះដូរ បាត់ខ្លួនអីដែរ?

ញ៉ន ៖ ហ៎! ទៅដល់គេនេះគេថាផ្លាស់ ។

វណ្ណៈ ផ្លាស់?

ញ៉ន ៖ ចា៎ស!

វណ្ណៈ ផ្លាស់ច្រើនគ្នាទេ?

ញ៉ន ៖ ច្រើន ញឹកញាប់ណាស់ ប៉ុនមិនដឹងទៅណាយើងចេះតាមគេអីចឹងដែរទៅ ។

វណ្ណៈ ផ្លាស់ញឹកញាប់?

ញ៉ន ៖ ចា៎ស! មើលខ្ញុំនៅប៉ុន្មានឆ្នាំនឹង២-៣ ។

វណ្ណៈ ហើយចុះអ្នកថ្មីមកទៀត?

ញ៉ន ៖ អ្នកថ្មីក៏ប៉ុននឹង ។

វណ្ណៈ ចូលអ្នកថ្មីមកទៀត?

ញ៉ន ៖ ចា៎ស!

វណ្ណៈ អីចឹងបន្តបន្ទាប់រហូតទៅ តៗគ្នា?

ញ៉ន ៖ ចា៎ស!

វណ្ណៈ	តែមិនដឹងទៅខាងណា?

ញ៉ូន ៖	អត់ដឹងទេ គេមិនឲ្យយើងដឹងទេ ។

វណ្ណៈ	ពេទ្យអស់នឹងដូចថាបាត់ៗទៅ មិនដឹងគេយកទៅខាងណាអីខាងណាទេ?

ញ៉ូន ៖	អត់ដឹង ។

វណ្ណៈ	អីចឹងមានការផ្លាស់ប្តូររហូត?

ញ៉ូន ៖	ចាស!

វណ្ណៈ	ឥឡូវខ្ញុំសួរទាក់ទងដែលអ៊ំរៀបការនៅឆ្នាំ៧៦ៗហ្នឹង អ៊ំរៀបការនឹងមានគិតទុកគ្នាជាមុន ឬក៏ឃើញគ្នាពីមុនមក ឬក៏អង្គការចាត់តាំងតែម្តង?

ញ៉ូន ៖	អា៧៦?

វណ្ណៈ	៧៦ដែលអ៊ំរៀបការជាមួយប្តីសេដ្ឋកិច្ច?

ញ៉ូន ៖	នៅជាមួយគ្នាដែរ នៅស្រុកនឹងគ្នាដូចគ្នា ។

វណ្ណៈ	តែអ៊ំដូចថា អ៊ំបានពេញចិត្តគ្នាទៅវិញទៅមក?

ញ៉ូន ៖	អត់ទេ អត់មានស្រឡាញ់មានអីទេ តែអង្គការថាបើយើងមិនយកគេវៃចោល ។

វណ្ណៈ	អ៊ំអត់បានស្រឡាញ់ទេ?

ញ៉ូន ៖	ចាស!

វណ្ណៈ	នៅក្រោយទេ ប៉ុន្តែអង្គការបង្ខំ?

ញ៉ូន ៖	ចាស!

វណ្ណៈ	តែនៅក្រោយ៧៩អ៊ំមិនបានលែងលះគ្នា គឺអ៊ំនៅជាមួយគ្នាទាល់តែស្លាប់?

ញ៉ូន ៖	នៅជាមួយគ្នារហូត ។

វណ្ណៈ	នៅជាមួយគ្នារហូតដល់គាត់ស្លាប់ទៅ?

ញ៉ូន ៖	ចាស!

វណ្ណៈ	ពេលដែលអ៊ំការនៅឆ្នាំ៧៦ហើយ តើគេបញ្ជូនអ៊ំមកខាងណាវិញ?

ញ៉ូន ៖	មកនៅសហករណ៍ ។

វណ្ណៈ	ប្តីអ៊ំមកដែរ?

ញ៉ូន ៖	មក ។

វណ្ណៈ	មកនៅសហករណ៍នឹង អ៊ំគេចាត់តាំងឲ្យធ្វើអីវិញទៅ?

ញ៉ូន ៖	ខ្ញុំដាំបាយ ។

វណ្ណៈ　ប្តីធ្វើអី?

ញ៉ន ៖　គាត់ខាងដាំដំណាំ ។

វណ្ណៈ　សេដ្ឋកិច្ច?

ញ៉ន ៖　ចា៎ស!

វណ្ណៈ　សេដ្ឋកិច្ចដដែល ព្រោះកាលនឹងអ្នកដាំដំណាំគេចាត់ទុកសេដ្ឋកិច្ចហើយ?

ញ៉ន ៖　ចា៎ស!

វណ្ណៈ　រហូតដល់បែក៧៩?

ញ៉ន ៖　ចា៎ស!

វណ្ណៈ　ពី៧៦រហូតដល់៧៩ តើនៅសហករណ៍នឹង ដូចថាគេហូបរួមរបៀបម៉េចទៅ?

ញ៉ន ៖　ហូបថ្ងៃណាវាឆ្អែតៗ ថ្ងៃណាមិនឆ្អែតក៏ហៃ ហើយបើថាគ្មានអីទេ ដំឡូងមីមួយរួចមួយពេល

វណ្ណៈ　ដំឡូងមី១ម្នាក់នឹង?

ញ៉ន ៖　ចា៎ស!

វណ្ណៈ　ដំឡូងមីម៉ាដុំអត់មានបាយមានអីទេ?

ញ៉ន ៖　អត់ទេ តែម៉ាគល់នឹង តែម៉ាចង្អាមនឹងហើយ ។

វណ្ណៈ　អីចឹងអត់មានសម្លមានអីទៀតទេ?

ញ៉ន ៖　គ្មានទេ គេឲ្យហើយចែកហើយៗ ។

វណ្ណៈ　នៅឆ្នាំណាដែលអ៊ំជួបការលំបាកជាងគេ?

ញ៉ន ៖　ឆ្នាំ៧៦នឹងម៉ង ។

វណ្ណៈ　៧៦អ៊ំចូលមកដល់នឹង?

ញ៉ន ៖　នៅសហករណ៍នឹង ។

វណ្ណៈ　នៅឆ្នាំ១៩៧៦ ប្រជាជនខ្វះអាហារ?

ញ៉ន ៖　ចា៎ស!

វណ្ណៈ　ខ្វះអាហារខ្លាំងម៉ង?

ញ៉ន ៖　ចា៎ស!

វណ្ណៈ　មានពេលខ្លះហូបតែដំឡូងមួយដុំ?

ញ៉ន ៖　មានពេលខ្លះតែមានពោត តែមួយវែកម្នាក់ដាក់នឹងបាននឹង ហូតជាមួយសម្លរទៅប៉ុននឹងរួចមួយពេលដែរ ។

វណ្ណៈ ពោតប៉ុន្មាន?

ញ៉ន ៖ ពោតតែម៉ាវែកយើងនឹង ។

វណ្ណៈ ១វែក ពោតឆៅ?

ញ៉ន ៖ ពោតស្ងោរទឹកកំបោរ ។

វណ្ណៈ គ្មានអាហារផ្សេងទេ ។ ចុះការហូបរបៀបនឹង តើប្រជាជនឈឺ មានឈឺកាន់តែច្រើន ហើមឈឺច្រើនស្លាប់ទេ?

ញ៉ន ៖ មាន អានឹងគេបញ្ជូនទៅស្រុក ។

វណ្ណៈ អីចឹងប្រជាជនឈឺហើមស្លាប់ច្រើនដោយសារអត់អាហារនឹង?

ញ៉ន ៖ ចា៎ស! អត់អាហារនឹង ។

វណ្ណៈ បើអ៊ំគិតមើលតើនៅស្រុកគិរីវង់នេះ ខាងថ្នាក់លើដូចថ្នាក់មជ្ឈិមដូចតាម៉ុកអី ទុកចិត្តអ្នកនៅជិតនេះដែរ ឬយ៉ាងម៉េច ពីព្រោះគិរីវង់នេះវាជាប់ព្រំដែនវៀតណាមដែរ ឬក៏គេមានចេតនាចង់ធ្វើបាបប្រជាជននៅនឹង ឬក៏យ៉ាងម៉េច បើតាមអ៊ំគិត?

ញ៉ន ៖ អត់ដឹងទេ ដល់ឆ្នាំ៧៦ ខ្ញុំមិនដឹងដែរមិនដែលឃើញមិនដែរអី បើនៅប្រជាជន ។

វណ្ណៈ ៧៦ អ៊ំមកនៅដាំបាយនៅសហករណ៍?

ញ៉ន ៖ ចា៎ស!

វណ្ណៈ សហករណ៍រហូត ដូចអ៊ំមានបងប្អូនបង្កើតស្លាប់ដោយសារសម័យនឹងដែរ?

ញ៉ន ៖ មាន ។

វណ្ណៈ មានឈ្មោះអីខ្លះ?

ញ៉ន ៖ ប៉ាវ ហាយ ។

វណ្ណៈ មួយទៀត?

ញ៉ន ៖ សំ ណាប់ នឹងស្លាប់ ។

វណ្ណៈ ស្លាប់ដោយសារអី យោធា?

ញ៉ន ៖ អានឹងស្លាប់ មិនយោធាទេ កាលនឹងគេទៅខ្មែរក្រហមនឹង កាលយើងទៅ ។

វណ្ណៈ ជម្លៀសទៅ?

ញ៉ន ៖ មិនទេ កាលទៅបរប៉ៃលិននឹង ។

វណ្ណៈ សម័យក្រោយ?

ញ៉ន ៖ ចា៎ស!សម័យហ្នឹង ។

វណ្ណៈ អត់ទេ ខ្ញុំចង់ដឹង អីចឹងអត់យក ៗ ខ្ញុំចង់ដឹងថាស្លាប់ជំនាន់អាពតមានទេ ជំនាន់ខ្មែរក្រហម មានទេ?

ញ៉ន ៖ មាន បាត់ខ្លួនអាប្អូនមួយនឹង ។

វណ្ណៈ ឈ្មោះអី?

ញ៉ន ៖ ឈ្មោះ ប៉ាវ ហាយនឹង អានឹងបាត់ខ្លួន ។

វណ្ណៈ យោធាបាត់ខ្លួន ។ អីចឹងអត់មានពីណាផ្សេងទៀតទេ សាច់ញាតិអីអី?

ញ៉ន ៖ អត់មាន ។

វណ្ណៈ អ៊ំដើរកាលនឹង អ៊ំដែលឃើញគេបណ្ដើរមនុស្សយកទៅវ៉ៃចោលទេ?

ញ៉ន ៖ ខ្ញុំមិនដែល ៗ សោះ ។

វណ្ណៈ ចុះនៅ តាំងនៅពេទ្យ តាំងនៅសហករណ៍?

ញ៉ន ៖ កាលនៅពេទ្យក៏មិនដែល ដែលឃើញស្លាប់នៅកន្លែងខ្លួនឯង ។

វណ្ណៈ អ្នកជម្ងឺស្លាប់ហ្នឹង?

ញ៉ន ៖ ចា៎ស!

វណ្ណៈ ចុះតាម៉ុកធ្លាប់មកប៉ុន្មានដង?

ញ៉ន ៖ មកម៉ាខែម្ដង ។

វណ្ណៈ អីចឹងតាម៉ុកមកម៉ាខែម្ដង ។ អ៊ំមកនៅសហករណ៍នឹងដូចថា ប្រជាជនម៉ាចំនួនត្រូវគេជម្លៀស ចេញពីភូមិ ឬក៏យ៉ាងម៉េច អ៊ំដឹងយ៉ាងម៉េចអ៊ំបានដឹង?

ញ៉ន ៖ កាលខ្ញុំមកនៅនឹង គេយកប្រជាជនជម្លៀសទៅ១០៨វិញ ផ្លាស់ទីលំនៅហើយអានឹង ។

វណ្ណៈ នៅឆ្នាំណា?

ញ៉ន ៖ ហីកាលនឹង៨០ប៉ុន្មានទេ ។

វណ្ណៈ ហ៎! ៨០ជាងចូលរដ្ឋកម្ពុជាហើយ?

ញ៉ន ៖ ៧០ ៗប៉ុន្មានទេ តែចូលមុនយើងរំដោះ២ឆ្នាំ ។

វណ្ណៈ កាលនឹងអ៊ំជម្លៀសចេញ?

ញ៉ន ៖ ចា៎ស!

វណ្ណៈ អ៊ំអត់ជម្លៀសទេ អ៊ំនៅនេះ?

ញ៉ន ៖ ខ្ញុំទៅដែរ ។

វណ្ណៈ ឲ្យអស់ម៉ាភូមិនឹង?

ញ៉ន ៖ អស់ម៉ាភូមិនឹង ។

វណ្ណៈ ទៅណា?

ញ៉ន ៖ ទៅនៅ១០៨នោះ ១០៨ ។

វណ្ណៈ ៧៨ៗតាមមើល?

ញ៉ន ៖ ចា៎ស!

វណ្ណៈ អីចឹងភូមិនឹងអត់មានពីណាគេនៅ?

ញ៉ន ៖ អានឹងគេមកផ្សេងទៀត ។

វណ្ណៈ នៅយោធានៅ ឬក៏ម៉េច?

ញ៉ន ៖ កាលនឹងមិនដឹងម៉េច ពួកខ្ញុំទៅ ។

វណ្ណៈ អ្នកភូមិទៅចេញទាំងអស់?

ញ៉ន ៖ អ្នកភូមិនឹងទៅចេញទាំងអស់រលីងម៉ាភូមិនឹង មិនដឹងម៉េច ។

វណ្ណៈ យើងអត់ដឹងទេ ថានៅកន្លែងនឹងធ្វើអី?

ញ៉ន ៖ ចា៎ស! កន្លែងធ្វើអី ។

វណ្ណៈ ចេញពីភូមិទៅនៅតំបន់១០៨?

ញ៉ន ៖ ចា៎ស!

វណ្ណៈ តំបន់ ឬក៏អី?

ញ៉ន ៖ អានឹងគេហៅ១០៨ តំបន់អីចឹង ។

វណ្ណៈ នៅណា តាកែវដែរ?

ញ៉ន ៖ នៅកើត អីចឹងកំពង់ជ្រៃ ខាងកើតកំពង់ជ្រៃ ។

វណ្ណៈ កំពង់ជ្រៃ ខេត្តអីគេ?

ញ៉ន ៖ តាកែវ ខាងកើតកំពង់ជ្រៃ ។

វណ្ណៈ កំពង់ជ្រៃខេត្តអីគេ?

ញ៉ន ៖ តាកែវនឹង ខាងកើតកំពង់ជ្រៃ ។

វណ្ណៈ ដល់ឆ្នាំណាត្រឡប់ចូលភូមិវិញ?

ញ៉ន ៖ ដល់ឆ្នាំ៧៩នឹង វាបានមកចូលវិញ ។

វណ្ណៈ ៧៩ចូលមកភូមិ?

ញ៉ន ៖ ចូលដល់ភូមិ ។

វណ្ណៈ មកដល់ក្នុងភូមិ តើអ៊ំមានដឹងហេតុការណ៍អីកើតឡើងខ្លះទេ មានដូចថាឃើញឆ្អឹង ឃើញស្អី ឬ ក៏យ៉ាងម៉េច?

ញ៉ិន : ក្នុងភូមិអត់មាន មានតែឆ្អឹងគោ ។

វណ្ណៈ ចុះឆ្អឹងគេសម្លាប់អី អត់មាន?

ញ៉ិន : អត់មាន ។

វណ្ណៈ ចុះនៅម្តុំនឹងមានគុកមានអី គុកសន្តិសុខអី?

ញ៉ិន : មាននៅបៀតភ្នំ ។

វណ្ណៈ ភ្នំអីអានឹង?

ញ៉ិន : អានឹងគេហៅភ្នំយើង ដឹងគេហៅភ្នំអី ភ្នំដប់ អានឹងគេវ៉ៃនឹង អត់មានគុកទេ កន្លែងគេវ៉ៃចោល ។

វណ្ណៈ ភ្នំអីគេ?

ញ៉ិន : អានឹងគេហៅ ត្រង់នឹងគេហៅដីរឆ្លងហើយ ត្រង់នឹង ។

វណ្ណៈ ភ្នំដីរឆ្លង?

ញ៉ិន : ចា៎ស! គេយកទៅវ៉ៃចោល ។

វណ្ណៈ អានឹងស្លាប់ច្រើន?

ញ៉ិន : ស្លាប់ច្រើន អានឹងខ្ញុំមិនដឹង ទាល់តែខ្ញុំមកឮគេនិយាយ ។

វណ្ណៈ ចុះនៅវត្តជិតនឹង ៧៩អីមក មានគេគាស់ឆ្អឹងដាក់ណា?

ញ៉ិន : ហ្នឹងអត់មាន គេគាស់ប្តីគាត់គេគាស់យកទៅដាក់វត្តភ្នំ ។

វណ្ណៈ ដាក់វត្តភ្នំ?

ញ៉ិន : ចា៎ស!

វណ្ណៈ ចុះវត្តព្រះធាតុមានទេ?

អ្នកជិខាងៈវត្តព្រះធាតុអត់ដឹង អត់ដែរទៅ ។

វណ្ណៈ ចុះវត្តនេះមានទេ?

ញ៉ិន : វត្តកំពែងគ្មានទេ ។

អ្នកជិតខាងៈវត្តកំពែងកាលមុនគាស់ពីភូមិនឹងដាក់វត្តកំពែង ដល់ឥឡូវ ។

វណ្ណៈ វត្តកំពែងគាស់ដាក់វត្តកំពែង?

អ្នកជិតខាងៈដល់នេះគេថាឲ្យហែលយកទៅដាក់វត្តភ្នំទាំងអស់ នៅចេតិយមួយនឹង ។

វណ្ណៈ គាស់ដាក់វត្តកំពែង រួចហើយ?

ញ៉ន ៈ យកទៅវត្តភ្នំ ។

វណ្ណៈ យកទៅវត្តភ្នំៗ នៅស្រុកអីគេ ស្រុកគីរីវង់?

ញ៉ន ៈ ស្រុកគីរីវង់ដដែល ។

អ្នកជិតខាងៈ វត្តមានព្រះ ។

វណ្ណៈ ឆ្អឹងច្រើនទេកាលនឹង?

អ្នកជិតខាងៈ ឆ្អឹងជិតពេញម៉ាចេតិយនឹង ឥឡូវវារលួសខ្លះហើយ ។

ញ៉ន ៈ ខ្ញុំមិនដឹងដែរ ។

អ្នកជិតខាងៈ ខ្ញុំមកបង្សុកូលរាល់ឆ្នាំ ។

ញ៉ន ៈ ខ្ញុំឃើញៗ ត្រង់សពនេះ អានឹងខ្មោចច្រើនមែន ។

វណ្ណៈ ខ្ញុំសួរអ៊ំតិចតួច ទាក់ទងនឹងបច្ចុប្បន្ននេះ យើងសព្វថ្ងៃមានតុលាការ អ៊ំមានដឹងតុលាការសព្វថ្ងៃ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម អ៊ំដឹងដែរ?

ញ៉ន ៈ គ្មានណា គ្មានដឹងទេ ។

វណ្ណៈ កាត់ទោសប៉ុលពតៗស្លាប់ហើយ កាត់ទោសខៀវ សំផន, នួន ជា, អៀង ធារិទ្ធ, ឌុចគេចប់រឿងក្តីគាត់ ហើយនៅចាំចេញសាលក្រមប្រកាសថាគាត់ត្រូវជាប់គុក ឬក៏រួចខ្លួន ។ តើអ៊ំអត់បានស្តាប់វិទ្យុ ឬវ៉ាដ្យូអីទេ?

ញ៉ន ៈ អត់មាន ។

វណ្ណៈ បើអ៊ំបានដឹងតាមរយៈខ្ញុំថា បើមានតុលាការសម្រាប់កាត់ទោសមេដឹកនាំខ្មែរក្រហម ដែលគេកំពុងធ្វើការសព្វថ្ងៃនឹង តើអ៊ំគិតថាជាការត្រឹមត្រូវ ឬក៏មិនត្រឹមត្រូវទេ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមធំៗនឹង?

ញ៉ន ៈ ដែរ មិនដែលដឹងដែលឮផង មិនដឹង ។

វណ្ណៈ ប៉ុន្តែអ៊ំគិតថាជាការត្រឹមត្រូវហើយ ឬក៏មិនត្រឹមត្រូវទេ មានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមចំនួន៥នាក់នឹងសព្វថ្ងៃ ព្រោះថ្នាក់ក្រោមគេមិនអាចធ្វើការកាត់ទោសទេ ពីព្រោះច្រើនណាស់ អ្នកណាក៏ចូលបដិវត្តចូលយោធា ចូលអីចឹង បម្រើបដិវត្តដែរ ប៉ុន្តែខាងក្រោយថ្នាក់តូចៗនឹង គេមិនបានទៅចាប់ ទៅអីទេ គឺគេក្នុងច្បាប់នឹងគេកំណត់យកអ្នកធំ អ្នកដែលមានមុខដំណែងខ្ពស់បំផុត មានតួនាទីធំៗ ដូចតុលាការសព្វថ្ងៃនឹង ។ តើអ៊ំថា ការកើតមានតុលាការនឹងជាការត្រឹមត្រូវដែរអត់?

ញ៉ន ៖ ត្រឹមត្រូវ ។

វណ្ណៈ ហេតុអីបានអ៊ំថាត្រឹមត្រូវ?

ញ៉ន ៖ ត្រឹមត្រូវនឹង ឲ្យដឹងខុសត្រូវ ។

វណ្ណៈ ចុះអ៊ំគិតថាតុលាការនឹងមានសារៈសំខាន់ ឬផលប្រយោជន៍អីដែរ?

ញ៉ន ៖ សារៈសំខាន់ហើយ រឿងបានត្រឹមត្រូវហើយ មិនសំខាន់ ។

វណ្ណៈ តុលាការនឹងអាចជួយរកយុត្តិធម៌ឲ្យបងប្អូនយើងបានទេ?

ញ៉ន ៖ បាន ។

វណ្ណៈ ហេតុអីបានអ៊ំជឿថាបាន?

ញ៉ន ៖ អីបាន ព្រោះថាយើងខុសដឹងខុស យើងត្រូវថាត្រូវ ។

វណ្ណៈ ហើយអ៊ំគិតថាតុលាការនឹងមានផលប្រយោជន៍អីសម្រាប់ប្រជាជនយើងដែរ?

ញ៉ន ៖ អានឹងសម្រាប់ថាយើងមានរឿង មានទោសអី អានឹងបានយើងទៅទីពឹងបាន ទៅនិយាយបានតវ៉ា ហើយបើថាយើងអត់មានទេ ដឹងតវ៉ាឯណាអត់មាន ។

វណ្ណៈ អ៊ីចឹងអ៊ំបានបម្រើជួរបដិវត្តអីចឹងមែន ហើយអ៊ំក៏មានចិតចង់ជួយដូចថាប្រជាជនដែលឈើញឈឺនៅពេទ្យអីដែរ តែអ៊ំគ្មានលទ្ធភាពជួយ ។

ញ៉ន ៖ ចា៎ស! អត់មាន ។

វណ្ណៈ យើងធ្វើការតាមបញ្ជាថ្នាក់លើ ។

ញ៉ន ៖ តាមបញ្ជាគេ ។

វណ្ណៈ អ៊ំមិនហ៊ានជំទាស់អីទេ?

ញ៉ន ៖ មិនហ៊ានជំទាស់ទេ តែជំទាស់ទេយកទៅ គេហៅទៅផ្ចាស់ តែវៃហើយគេហៅទៅផ្ចាស់ ។

វណ្ណៈ អ៊ីចឹងអ៊ំមានអីចង់បន្ថែមទៀត ដែលខ្ញុំមិនបានសួរអ៊ំ?

ញ៉ន ៖ អត់មានអីទៀតទេ ។

វណ្ណៈ អ៊ីចឹងខ្ញុំអរគុណអ៊ំច្រើន ។

ញ៉ន ៖ ចា៎ស!

«ចប់»